**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿងរដ្ឋប្បវេណី
លេខៈ ១៨
ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩៨
**សាលដីកា**
លេខៈ ២៣២
ចុះថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦
ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅៈ
១- ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣- លោក ............... ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក .............. ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
លោក................។

**តំណាងមហាអយ្យការ**
លោក ...................ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៦៥៣ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧នៃសំណុំរឿងរដ្ឋប្បវេណីលេខ៩៩ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាលទុក្ខឈ្មោះ រ ប្តីរបស់ឈ្មោះ ប្រាក់ សារ៉ាម អាយុ ៤០ ឆ្នាំ ជាតិខ្មែរ របររកស៊ី ធ្វើយោធា ទីលំនៅ ផ្ទះលេខ ២០អឺអង ក្រុមទី៣៦ផ្លូវលេខ ៦០៨ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ។ ឪពុកឈ្មោះ រ "រ" ម្តាយឈ្មោះ និល ចាយ "ស" ប្រពន្ធឈ្មោះ ប្រាក់ សារ៉ាយ មានកូន ០៣នាក់ ។

នឹងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ រគន គេទស្រី អាយុ ៤២ ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះទីលំនៅផ្ទះលេខ ៦០៨ ក្រុមទី៣៦ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ឪពុកឈ្មោះ រៀល កេង ""ម្តាយឈ្មោះ ព្រំពិន "" ។

កម្មវត្ថុបណ្តឹង ៖ ប្តឹងទាមទារប្រាក់ចំនួន២១០០ដុល្លាអាមេរិក ។

តាមបណ្តឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ឡុង លាភី បានប្តឹង-មិនសុខចិត្តនិងសេចក្តីសំរេចនៃសាលដីកាលេខ ១១៧ ចុះថ្ងៃទី ២៣ ខែមិនាឆ្នាំ ១៩៩៨ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤២៩ ចុះថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់ឈ្មោះរ ប្តីរបស់ឈ្មោះ ប្រាក់ សារ៉ាម ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៦៥៣ ចុះថ្ងៃទី៤.១១.៩៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំនុចនៃសេចក្តីសំរេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៨ចុះថ្ងៃទី១៦ ខែ មករា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១១.១០.៩៤ របស់ឈ្មោះ រគន ប្តឹងពីឈ្មោះ ប្រាក់ សារ៉ាម ហៅ ម៉ែ អារិ ទ្ធិ ដោយសំអាងថាបានខ្ចីប្រាក់ខ្លួនចំនួន២១០០ ដុល្លាអាមេរិក កាលពីថ្ងៃទី ៨.១០.៩៤ មកដល់សព្វថ្ងៃឈ្មោះនេះពុំព្រមសងខ្លួនទេហើយរត់ចេញពីផ្ទះទៀតដូចនេះខ្លួនសូមអោយតុលាការរកយុត្តិធម៌អោយខ្លួនដោយអនុគ្រោះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤៤៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៤ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

សាលដីការដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ រគន ចុះថ្ងៃទី ១១.១០.៩៤ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បង្គាប់អោយឈ្មោះ ប្រាក់ សារ៉ាមសងប្រាក់ចំនួន ២១០០ដុល្លារទៅអោយឈ្មោះរៀលគឹមនីវិញ

ករណីពុំព្រមសងត្រូវរឹបអូសផ្ទះលេខ ២៩ អឺអង ផ្លូវលេខ ៦០៨ ក្រុមទី៣៦សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ លក់ឡាយឡុងជានាសំណងតាមច្បាប់ស្តីពីនិតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៣-បង្គាប់អោយឈ្មោះ ប្រាក់ សារ៉ាម ចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីពន្ធចុះបញ្ជីក្តី ពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីហឹបប្រាក់២០០រៀល អ្នកប្រគល់ដីកាកោះ ៤០០០រៀល បូករួម៦០០០រៀលប្រាក់នេះបានកាត់យកពីប្រាក់៧០០០រៀលដែលដើមចោទបានបង់ទុកជាស្រេចនៅសល់ ១០០០រៀលប្រគល់អោយដើមចោទវិញ

កាលបើហួសបណ្តឹងឧទ្ធរណ៍ហើយបង្គាប់អោយចុងចម្លើយសងប្រាក់៧០០០រៀលទៅអោយដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រ$\frac{\text{១គុណ២១០០}}{\text{១០០}}$: ២១ដុល្លាបន្ថែមទៀតដែលត្រូវដាក់ចូលថវិការដ្ឋ $\frac{\text{៨០គុណ២១}}{\text{១០០}}$: ១៦,៨ ដុលល្លា និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស $\frac{\text{២០គុណ១៦,៨}}{\text{១០០}}$: ៣,៣៦ដុល្លា

៤-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយសំរេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី ១២ខែ មករា ឆ្នាំ ១៩៩៥ របស់ឈ្មោះ រឿង រ៉ន មិនសុខចិត្តត្រង់ចំនុចទី២ នៃសាលក្រម ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦៤ "គ" ចុះថ្ងៃទី ៣០ ខែ មិតុនា ឆ្នាំ ១៩៩៥ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះ រឿង រ៉ន ចុះថ្ងៃទី ១២.០១.៩៥ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែត្រូវបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។

២- តំកល់សាលក្រមលេខ ៤៤៣ចុះថ្ងៃទី២៧.១២.៩៤ ទុកជាបានការពេញទាំងមូល ។

៣- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគីសំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែគិតចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ ១៩៩៥ របស់ឈ្មោះ រឿង រ៉ន ប្តឹងមិនសុខចិត្តនិងសាលក្រមរដ្ឋប្បវេណីលេខ៦៤ "គ" ចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ១៩៩៥របស់តុលាការក្រុងភ្នំពេញ ត្រង់ចំនុច រឹបអូសផ្ទះលេខ ២៩អឺអងផ្លូវ៦០៨ក្រុមទី៣៦សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញលក់ឡាយឡុង ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៥៣ចុះថ្ងៃទី០៤ ខែ វិច្ឆិកាឆ្នាំ ១៩៩៧របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២២.០៨.៩៥ របស់ឈ្មោះ រឿង រ៉ន "ប្តីប្រាក់ សារ៉ាម" ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែលើកចោលដោយទាស់និង គតិច្បាប់ ។

សាលដីការដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨របស់ តុលាការកំពូល ។

២- តម្កល់សាលក្រមលេខ ៦៤ "ក" ចុះថ្ងៃទី ៣០.០៦.៩៥ របស់តុលាការក្រុងភ្នំពេញទុកជាបានការពេញទាំងមូលដ៏ដែល ។

៣- សំរេចរឹបអូសប្រាក់ប្រដាប់ដ្ឋីដាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺពន្ធហ៊ឹងនិងពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០រៀល ចំណាយលើអ្នកប្រគល់ដីកាកោះ ៥.០០០រៀលនិង អាផ្លាធរតុលាការ៥០០០រៀល សរុប ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈបចំពោះមុខចុងបណ្តឹងឧទ្ធរណ៍កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤២៩ ចុះថ្ងៃទី ១១ ខែ វិច្ឆិកាឆ្នាំ ១៩៩៧ របស់ឈ្មោះរឿង រ៉ន ប្តីរបស់ឈ្មោះ ប្រាក់ សារ៉ាម ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៦៥៣ ចុះថ្ងៃទី ០៤.១១.៩៧របស់សាលាឧទ្ធរណ៍លើចំនុចនៃសេចក្តីសំរេចទាំងមូលធ្វើឡើងក្នុងកំណាត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ២៣ ខែ កុម្ភះ ឆ្នាំ ១៩៩៨របស់ឈ្មោះ រឿង រ៉ន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍បានសំរេចផ្ទុយនិងគតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ រឿង រ៉ន ប្តីរបស់ឈ្មោះប្រាក់ សារ៉ាម ជាម្ចាស់បណ្តឹងសាទុក្ខនិងជាភាគីចុងចម្លើយនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា ៖ ប្រពន្ធខ្ញុំខ្ចីលុយគេខ្ញុំមិនដឹងឮទេគ្មានភស្តុតាងខ្ញុំមិនទទួលស្គាល់ទេរឿងជំពាក់ប្រាក់នេះប្រពន្ធខ្ញុំរត់បាត់នៅឆ្នាំ១៩៩៤សល់តែកូន០៤នាក់ ។ សូមតុលាការកំពូលបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ រកយុត្តិធម៌អោយខ្ញុំ ។

បានស្តាប់ចម្លើរបស់ឈ្មោះ រគន ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា ៖ ប្រពន្ធគាត់ខ្ចីខ្ញុំពុំប្តឹងអោយគាត់សងលុយនេះខ្ញុំខ្ចីពីគេដែរ ។ ប្រពន្ធគាត់ដើរបោកប្រាស់គេ សព្វថ្ងៃខ្ញុំជាអ្នកចេញសងជំនួសគេ ការខ្ចីឥតមានលិខិតស្នាមទេមានសាក្សីដឹងឮ ។ សូមតុលាការរកយុត្តិធម៌អោយខ្ញុំផង ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាបចម្លើយ ដោះសាររបស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា ៖ បណ្តឹសាទុក្ខលេខ ៤២៩ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់លោករឿងរ៉នប្តីរបស់អ្នកស្រីប្រាក់ សារ៉ាយធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា ៖ ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការក្រុងភ្នំពេញដែរដែលសំរេចរឹបអូសផ្ទះលេខ 20E1

សាលដីការដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨របស់តុលាការ កំពូល ។

ផ្លូវ៦០៨ក្រុមទី៣៦សង្កាត់បឹងកក់២ខ័ណ្ឌទួលគោក ក្រុងភ្នំពេញលក់ឡាយឡុងនោះគឺជាការបំពានទៅលើសមាត្រា៣៥ចំនុច២ និងមាត្រា៣៧ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារពីព្រោះពុំមានភស្តុតាងណាបញ្ជាក់ថាផ្ទះនេះជាកម្មសិទ្ធិដោយឡែករបស់អ្នកស្រីប្រាក់ សារ៉ាម ឡើយ ។

- យល់ឃើញថា ៖ លោក រ ប្តឹងទៅសាលាឧទ្ធរណ៍ ក្នុងនាមជាតតីយជន ប៉ុន្តែសាលាឧទ្ធរណ៍មិនបានបញ្ចូលលោក រ ជាតតីយជន ឡើយហើយបែរជាសំរេចសេចក្តីក្នុងនាមជាចុងចម្លើយទៅវិញ ។
- យល់ឃើញថា ៖ លោក រ ប្តឹងទៅសាលាឧទ្ធរណ៍តែពីចំនុចរឹបអូសផ្ទះលក់ឡាយឡុងផ្ទះលោកតែប៉ុណ្ណោះ ប៉ុន្តែសាលាឧទ្ធរណ៍បែរជាសំរេចសេចក្តីលើសពីការសុំ របស់លោក រ ទៅវិញ ។
- យល់ឃើញថា ៖ សាលដីការដ្ឋប្បវេណីលេខ ៦៥៣ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់សាលាឧត្ធរណ៍ដែលសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៤២៩ចុះថ្ងៃទី ១១ខែ ឧសភា ឆ្នាំ ១៩៩៧របស់លោក រ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៦៥៣ ចុះថ្ងៃទី ០៤ខែ វិច្ឆិកាឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៨ចុះថ្ងៃទី១៦ខែមករាឆ្នាំ១៩៩៨របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក រ បានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀលគឺ៖

- ពន្ធចុះបញ្ជីក្តីនិង ពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០រៀលសរុប ១៩.០០០រៀលហើយតម្រូវអោយអ្នកស្រីរគន សងប្រាក់ចំនួន១៩.០០០រៀលនេះទៅលោក រេ វិញ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ។